ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ

# កំណត់ហេតុ
## ស្តីពី
## មហាសន្និបាតភាគហ៊ុនិក លើកទី១ របស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ

ថ្ងៃ ពុធ ៥ កើត ខែ ចេត្រ ឆ្នាំ រកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ វេលាម៉ោង ០៨:០០ នាទីព្រឹក នៅសាលប្រជុំធំ នៃអគារទីចាត់ការកំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) បានរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី១ ដោយមានរបៀបវារៈរាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម, ហិរញ្ញវត្ថុឆ្នាំ២០១៧, ទិសដៅការងារឆ្នាំ២០១៨ និងការបោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ ចំនួន ០១ រូប និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ចំនួន ០១ រូប ជាសមាជិកក្រុមប្រឹក្សាភិបាល កសស សម្រាប់អាណត្តិទី៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **លូ គឹមឈន់** ប្រធានក្រុមប្រឹក្សាភិបាល និងជាប្រធានមហាសន្និបាតភាគហ៊ុនិកលើកទី១ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) ។

- <u>គណៈអធិបតី រួមមាន៖</u>

| | |
|---|---|
| ១. ឯកឧត្តម **ស៊ួន ហេង** | រដ្ឋលេខាធិការ តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន |
| ២. ឯកឧត្តម **ផាន់ ផល្លា** | សមាជិកក្រុមប្រឹក្សាភិបាល, អាណត្តិគាហកៈ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាតំណាង ឯកឧត្តមបណ្ឌិតសភាចារ្យ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៣. ឯកឧត្តម **តឹករ៉េត សំរេច** | សមាជិកក្រុមប្រឹក្សាភិបាល តំណាងទីស្តីការគណៈរដ្ឋមន្ត្រី |
| ៤. ឯកឧត្តម **ស៊ុយ សាន** | សមាជិកក្រុមប្រឹក្សាភិបាល តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន |
| ៥. ឯកឧត្តម **សុខ សុភ័ក្ត្រ** | សមាជិកក្រុមប្រឹក្សាភិបាល តំណាងក្រសួងពាណិជ្ជកម្ម |
| ៦. ឯកឧត្តម **សៀង ធីរិទ្ធ** | អគ្គនាយករង នៃគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) |
| ៧. លោក **ល្មុន សុខឡី** | តំណាង ផ្សារមូលបត្រកម្ពុជា (ផ.ម.ក) |
| ៨. លោក **លូ លីខេង** | សមាជិកក្រុមប្រឹក្សាភិបាល តំណាងនិយោជិត កសស |
| ៩. លោក **ព្រំ សេង** | មន្ត្រីត្រួតពិនិត្យរដ្ឋអម កសស |

- <u>ភ្ញៀវកិត្តិយស រួមមាន៖</u>

| | |
|---|---|
| ១. Mr. **SHAKATA** | តំណាង ក្រុមហ៊ុន SBIR |
| ២. លោក **ហោ ស៊ីម៉េត** | តំណាង អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី |
| ៣. លោក **គុយ លីម** | តំណាងក្រុមហ៊ុន PWC |
| ៤. លោក **ឡាង ហ៊ី** | តំណាងក្រុមហ៊ុន PWC |
| ៥. អ្នកស្រី **ហ៊ី ផានិន** | អគ្គនាយករង កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ) |

| | |
|---|---|
| ៦. លោកស្រី **នាន មុនី** | ប្រធាននាយកដ្ឋាន គ្រប់គ្រងការបោះផ្សាយមូលបត្រ នៃគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) |
| ៧. កញ្ញា **ជា យ៉ាអ៊ីម** | ប្រធានការិយាល័យអភិបាលកិច្ចសាជីវកម្ម នៃនាយកដ្ឋាន គ្រប់គ្រងការបោះផ្សាយមូលបត្រ |
| ៨. លោក **សុខ ចិត្រា** | មន្ត្រីជំនាញ នៃការិយាល័យអភិបាលកិច្ចសាជីវកម្ម នៃនាយកដ្ឋាន គ្រប់គ្រងការបោះផ្សាយមូលបត្រ |
| ៩. លោក **សេខ ឈាខឡាយ** | មន្ត្រីជំនាញ នៃការិយាល័យអភិបាលកិច្ចសាជីវកម្ម នៃនាយកដ្ឋាន គ្រប់គ្រងការបោះផ្សាយមូលបត្រ |
| ១០. លោក **ហៃ លីដេត** | មន្ត្រីជាន់ខ្ពស់នៃនាយកដ្ឋានចុះបញ្ជីមូលបត្រ និងឯកសារផ្តល់ព័ត៌មាន នៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា |
| ១១. លោក **ឃឹុង កុយ** | តំណាង ភ្នាក់ងារនាវាចរកម្ពុជា (កាំសាប) |
| ១២. Mr. **YAMAMOTO Yasuji** | JICA Expert to PAS |
| ១៣. Mr. **YABUNAKA Katsuichi** | JICA Expert to PAS |

ជាបឋម ឯកឧត្តម **លូ គឹមឈន់** ប្រធានក្រុមប្រឹក្សាភិបាល និងប្រធានមហាសន្និបាតភាគហ៊ុនិក បានឡើងមានមតិស្វាគមន៍គណៈអធិបតី ភ្ញៀវជាតិ-អន្តរជាតិ និងអង្គសន្និបាតទាំងមូល និងលើកឡើងអំពីខ្លឹមសារសំខាន់លើការងារអាជីវកម្ម ការអភិវឌ្ឍន៍ជាបន្តបន្ទាប់ ជាពិសេសលើការជ្រើសតាំងអភិបាលថ្មីចំនួន ០២ រូប ដើម្បីក្លាយខ្លួនជាសមាជិកក្រុមប្រឹក្សាភិបាល សម្រាប់អាណត្តិទី៧ ដែលរួមមានអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ជាមួយនឹងគោលការណ៍ក្នុងការបោះឆ្នោតជ្រើសតាំងអភិបាលទាំងពីររូបនេះ ។

ឯកឧត្តមប្រធានមហាសន្និបាត បានជម្រាបជូនអំពីវត្តមានភាគហ៊ុនិកមានចំនួន ១១៩ (មួយរយដប់ប្រាំបួន) រូប ស្មើនឹង ៨១.៤៧៩.៣៣៨ ភាគហ៊ុន តំណាងអោយ ៩៥% នៃភាគហ៊ុនសរុប ដែលកូរ៉ុមនេះអាចដំណើរការមហាសន្និបាតភាគហ៊ុនិកបាន ។

បន្ទាប់មក ដើម្បីអោយអង្គសន្និបាតភាគហ៊ុនិកលើកទី១ ដំណើរការពេញលក្ខណៈ ឯកឧត្តមប្រធាន បានជម្រាបជូនអង្គសន្និបាតភាគហ៊ុនិកទាំងមូល និងសូមការអនុម័ត ក្រុមលេខាកត់ត្រា ចំនួន ០៤ រូប ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. លោក វ័ត្ន សិលា | នាយក រដ្ឋបាល-ធនធានមនុស្ស | ជាប្រធាន |
| ២. លោក ពិត ប្រាកដ | នាយក អាជីវកម្ម | ជាអនុប្រធាន |
| ៣. លោក ម៉ែន ចាន់ | នាយក សវនកម្មផ្ទៃក្នុង | ជាអនុប្រធាន |
| ៤. លោក សាន ឈន់ | មន្ត្រី នា. រដ្ឋបាល-ធនធានមនុស្ស | ជាសមាជិក |

អង្គសន្និបាតបានយល់ព្រមលើសមាសភាពក្រុមលេខាកត់ត្រា ដោយលើកដៃអនុម័ត ។

បន្ទាប់ពីបញ្ចប់ការថ្លែងសុន្ទរកថារបស់ឯកឧត្តមប្រធានមហាសន្និបាត និងការអនុម័តក្រុមលេខាកត់ត្រា នៅម៉ោង ០៨:៤៥ នាទី ឯកឧត្តមប្រធានអង្គមហាសន្និបាត បានអនុញ្ញាតអោយលោក **អ៊ុក សុមេធី** ប្រធានការិយាល័យស្ថិតិ បានឡើងរាយការណ៍ពីលទ្ធផលការងារអាជីវកម្ម, ហិរញ្ញវត្ថុឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ ២០១៨ ។

១. របាយការណ៍ លទ្ធផលអាជីវកម្ម សេវាកម្ម ឆ្នាំ ២០១៧ ធៀបនឹងឆ្នាំ២០១៦

- បរិមាណទំនិញឆ្លងកាត់ផែ ៤.៣៦៤.៦៣៨ តោន កើនឡើង ៨,០៣%
- បរិមាណជាកុងតេន័រឆ្លងកាត់ ៤៥៩.៨៣៩ TEUs កើនឡើង ១៤,៩១%
- ចំនួននាវាចូលចតគិតជាគ្រឿង ១.៣០៥ គ្រឿង ថយចុះ -១,២៩%
- ទំនិញកុងតឺន័រដឹកជញ្ជូនតាមរថភ្លើង ៤១.៥៩៨ TEUs កើនឡើង ៣១,៩៦% ។

២. លទ្ធផលហិរញ្ញវត្ថុ ឆ្នាំ២០១៧

២.១ របាយការណ៍ ស្ថានភាពហិរញ្ញវត្ថុ (មិនបានធ្វើសវនកម្ម)

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ (ពាន់រៀល) (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ (ពាន់រៀល) (បានធ្វើសវនកម្ម) |
|---|---|---|
| ទ្រព្យសកម្ម | | |
| - ទ្រព្យសកម្មរយៈពេលវែង | ១.១០៦.៤០៥.២២២ | ១.០០២.៩០០.៣៣៤ |
| - ទ្រព្យសកម្មរយៈពេលខ្លី | ១៧៤.១០៤.៨១៦ | ៨០.០៣១.៣១៣ |
| **ទ្រព្យសកម្មសរុប** | **១.២៨០.៥១០.០៣៨** | **១.០៨២.៩៣១.៦៤៧** |
| មូលធន និងបំណុល | | |
| **មូលធន** | **៦៤៦.៦១០.៥៥៤** | **៥៣៤.៦១៣.០១១** |
| **បំណុល សរុប** | **៦៣៣.៨៩៩.៤៨៤** | **៥៤៨.៣១៨.៦៣៦** |
| - បំណុលរយៈពេលវែង | ៥៦៧.៣១៤.១៣៥ | ៥០៩.៤៦៥.១១៨ |
| - បំណុលរយៈពេលខ្លី | ៦៦.៥៨៥.៣៤៩ | ៣៨.៨៥៣.៥១៨ |
| **មូលធន និងបំណុលសរុប** | **១.២៨០.៥១០.០៣៨** | **១.០៨២.៩៣១.៦៤៧** |

២.២ របាយការណ៍ ចំណេញ-ខាត (ដំណាច់ការិយបរិច្ឆេទ ៣ខែ ឆ្នាំ ២០១៧)

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ (ពាន់រៀល) (បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ (ពាន់រៀល) (មិនបានពិនិត្យ និងមិនបានធ្វើសវនកម្ម) |
|---|---|---|
| **ចំណូល** | **៦២.៨៤៣.០០០** | **៥៣.១១៥.១៧១** |
| ចំណាយប្រតិបត្តិការ | -៤៩.៥៤៧.៣០២ | -៤៨.៥៩៩.៨១៤ |
| **ចំណេញប្រតិបត្តិការ** | **១៣.២៩៥.៦៩៨** | **៤.៥១៥.៣៥៧** |
| ចំណូល/(ចំណាយ) ហិរញ្ញប្បទាន-សុទ្ធ | -១.៦០៩.៩៩៤ | -៥៣.៦៧០.៨១៧ |
| ចំណេញមុនបង់ពន្ធ | ១៤.៩០៥.៦៩២ | ៥៨.១៨៦.១៧៤ |
| ចំណាយពន្ធលើប្រាក់ចំណេញ | -៣.២៨១.៤២៥ | -១.៦១៥.៨៤០ |
| **ចំណេញក្នុងការិយបរិច្ឆេទ** | **១១.៦២៤.២៦៧** | **៥៦.៥៧០.៣៣៤** |

២.៣ របាយការណ៍ ចំណេញ-ខាត (ដំណាច់ការិយបរិច្ឆេទ ១២ ខែ ឆ្នាំ ២០១៧)

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧<br>(ពាន់រៀល)<br>(បានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្ម) | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦<br>(ពាន់រៀល)<br>(បានធ្វើសវនកម្ម) |
|---|---|---|
| ចំណូល | ២២៧.៣៩៧.៨៣៥ | ២០៨.៩៨១.២៤៩ |
| ចំណាយប្រតិបត្តិការ | -១៦៨.៩៩១.៤៩៥ | -១៥៤.៣៦៦.៥៧៨ |
| ចំណេញប្រតិបត្តិការ | ៥៨.៤០៦.៣៤០ | ៥៤.៦១៤.៦៧១ |
| ចំណូល/(ចំណាយ) ហិរញ្ញប្បទាន-សុទ្ធ | -២០.៥៥១.៧០៨ | -១៨.៧៦៨.៤៩៦ |
| ចំណេញមុនបង់ពន្ធ | ៣៧.៨៥៤.៦៣២ | ៣៥.៨៤៦.១៧៥ |
| ចំណាយពន្ធលើប្រាក់ចំណេញ | -១២.៧១៥.៣១៦ | -៩.១២៥.៧០៣ |
| ចំណេញក្នុងការិយបរិច្ឆេទ | ២៥.១៣៩.៣១៦ | ២៦.៧២០.៤៧២ |

៣. របាយការណ៍ លទ្ធផលអាជីវកម្ម សេវាកម្ម ០២ ខែ ដើមឆ្នាំ ២០១៨ ធៀបនឹង ០២ខែ ដើមឆ្នាំ ២០១៧

- បរិមាណទំនិញឆ្លងកាត់ផែ ៨៦៣.២០៨ តោន កើនឡើង ៣៤,៣៥ %
- បរិមាណជាកុងតឺន័រឆ្លងកាត់ ៨៣.៨០៧ TEUs កើនឡើង ២៧,៥៨%
- ចំនួននាវាចូលចតគិតជាគ្រឿង ២៣១ គ្រឿង ថយចុះ - ២,១២%
- ការនាំចូលធ្យូងថ្មបានត្រលប់មកប្រើប្រាស់សេវារបស់កំពង់ផែវិញ ដោយដើមឆ្នាំ ២០១៨ នេះមានសាឡង់ចំនួន ០២ គ្រឿងបានចូលចត ដែលក្នុងមួយសាឡង់ៗផ្ទុកធ្យូងថ្មប្រមាណជាង ៩.០០០ តោន ។

៤. ផែនការអាជីវកម្ម (សេវាកម្ម) និងវិនិយោគ ឆ្នាំ ២០១៨

៤.១. ផែនការអាជីវកម្ម (សេវាកម្ម) ឆ្នាំ ២០១៨

ដូចខាងក្រោម៖

- **បរិមាណទំនិញឆ្លងកាត់ផែ ៤.៥៦៣.០០០ តោន កើនឡើង ៤,៥៤ %**
  - បរិមាណទំនិញនាំចូល ៣.៣៤០.០០០ តោន កើនឡើង ៤,៨០ %
  - បរិមាណទំនិញនាំចេញ ១.២២៣.០០០ តោន កើនឡើង ៣,៨៤ %
- **សរុបតោនលើកដៀប ៦.២០៤.០០០ តោន កើនឡើង ៣,៥៣ %**
  - ប្រគល់ផ្ទាល់ ២៤៥.០០០ តោន កើនឡើង ២៤,២៩ %
  - ឆ្លងកាត់ឃ្លាំង-ទីលាន ៥.៩៥៩.០០០ តោន កើនឡើង ២,៨៣ %
- **កុងតឺន័រឆ្លងកាត់ ៤៩១.០០០ TEUs កើនឡើង ៦,៧៨ %**
  - កុងតឺន័រនាំចូល ២៤៧.០០០ TEUs កើនឡើង ៥,៧៣ %
  - កុងតឺន័រនាំចេញ ២៤៤.០០០ TEUs កើនឡើង ៧,៨៦ %
- **ចំនួននាវាចូលចតជាគ្រឿង ១.៣០០ គ្រឿង ថយចុះ -០,៣៨ %**

### ៤.២. ផែនការវិនិយោគឆ្នាំ ២០១៨

- **ការដ្ឋានប្រើប្រាស់កម្ចី ODA ជប៉ុន ចំនួន ១៣.០៣១.៤៥០ ដុល្លារអាមេរិក**
    - គម្រោងអភិវឌ្ឍចំណតផែពហុបំណង (CP-P10) ចំនួន ១១.៦១០.០០០ ដុល្លារអាមេរិក
    - គម្រោងអភិវឌ្ឍចំណតផែកុងតឺន័រថ្មី (CP-P21) ចំនួន ១.៤២១.៤៥០ ដុល្លារអាមេរិក
- **ថវិកា IPO និងមូលនិធិអភិវឌ្ឍ របស់ កសស ចំនួន ១៦.៣៣៣.០០០ ដុល្លារអាមេរិក**
    - បំពាក់ QC បន្ថែមចំនួន ០១ គ្រឿង ប្រើប្រាស់ថវិកាចំនួន ៧ លានដុល្លារអាមេរិក
    - បំពាក់ RTG បន្ថែមចំនួន ០៣ គ្រឿង ប្រើប្រាស់ថវិកាចំនួន ៤,៥ លានដុល្លារអាមេរិក
    - ទិញរថយន្តដឹកកុងតឺន័រចំនួន ១០ គ្រឿង ប្រើប្រាស់ថវិកាចំនួន ២,៥ លានដុល្លារអាមេរិក
    - បំពាក់គ្រឿងចក្រលើកដាក់សមត្ថភាព ៣០តោន ចំនួន ០១ គ្រឿង ប្រើប្រាស់ថវិកាចំនួន ៧២០.០០០ ដុល្លារអាមេរិក
    - រៀបចំបណ្តាញអគ្គិសនីក្នុងតំបន់ **កសស** ប្រើប្រាស់ថវិកាចំនួន ៤៥០.០០០ ដុល្លារអាមេរិក
    - អ៊ុតកៅស៊ូផ្លូវមុខតំបន់ **កសស** ប្រើប្រាស់ថវិកាចំនួន ២៨៦.០០០ ដុល្លារអាមេរិក
    - អ៊ុតកៅស៊ូតំបន់សេដ្ឋកិច្ចពិសេស **កសស** ប្រើប្រាស់ថវិកាចំនួន ៣៨២.០០០ ដុល្លារអាមេរិក
    - បញ្ជាទិញ ក្បាលសណ្តោង និង កន្ទុយសណ្តោង សម្រាប់ដឹកគ្រឿងចក្រ ប្រើប្រាស់ថវិកាចំនួន ២៥០.០០០ ដុល្លារអាមេរិក
    - ឧបករណ៍ប្រព័ន្ធប្រតិបត្តិការទីលានកុងតឺន័រ (CTMS +SWSS) ប្រើប្រាស់ថវិកា ២៤៥.០០០ ដុល្លារអាមេរិក ។

## ៥. គម្រោងអភិវឌ្ឍ

### ៥.១. គម្រោងអភិវឌ្ឍចំណតផែពហុបំណង កសស

- រហូតដល់ដំណាច់ខែកុម្ភៈ ឆ្នាំ២០១៨ ការងារសាងសង់ចំណតផែពហុបំណង កសស សម្រេចបានប្រមាណ ៩៤% នៃផែនការគ្រោងទុក ហើយគ្រោងដាក់អោយដំណើរការនៅពាក់កណ្តាល ឆ្នាំ២០១៨ ខាងមុខនេះ ។

### ៥.២. គម្រោងអភិវឌ្ឍស្ថានីយកុងតឺន័រថ្មី ជំហានទី១

- សាងសង់ចំណតផែកុងតឺន័រប្រវែង ៣៥០ ម៉ែត្រ ជម្រៅទឹក -១៤,៥ ម៉ែត្រ
- តម្លៃគម្រោង ២០៣ លានដុល្លារអាមេរិក
- កាលបរិច្ឆេទ ចាប់ផ្តើមសាងសង់ : ពាក់កណ្តាលឆ្នាំ ២០២០
- កាលបរិច្ឆេទបញ្ចប់ការសាងសង់ : ពាក់កណ្តាលឆ្នាំ ២០២៣ ។
- ចំពោះ កញ្ចប់ថវិកា
    - កញ្ចប់ទី១ : ហេដ្ឋារចនាសម្ព័ន្ធ (Infrastructure)
        - សាងសង់ចំណតផែ ៣៥០ ម៉ែត្រ ជម្រៅទឹក -១៤.៥ ម៉ែត្រ
        - ការងារបូមស្តារអាង និងឃ្លងនាវា
        - ការងារចាក់ដីបំពេញសាងសង់ទីលាន
        - សាងសង់ស្ពានផ្លូវចូលចំណតផែថ្មី
        - ការចាក់ដីបំពេញសម្រាប់ជាទីតាំងត្រួតពិនិត្យទំនិញរបស់ គយ និងរដ្ឋាករ
        - សាងសង់អាគារជួសជុល ថែទាំ

- ប្រព័ន្ធបង្ហូរទឹក ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធអគ្គីសនី និងសម្បទាផ្សេងៗ
- កញ្ចប់ទី២ : គ្រឿងចក្រទំនើបធន់ធ្ងន់ (Super Infrastructure)
  - មធ្យោបាយលើកដាក់កុងតឺន័រ៖
    - QC Cranes (Port Panamax-14 ជួរ) ០៣ គ្រឿង
    - RTG Cranes (6 ជួរ, 5+1 ជាន់) ០៩ គ្រឿង
    - Reach Stacker (10 តោន) ០២ គ្រឿង
    - រថយន្តសណ្តោង និងរ៉ឺម៉ក (កុងតឺន័រ ៤០') ១៦ គ្រឿង
    - ប្រព័ន្ធ CCTV ០១ គ្រឿង
    - ប្រព័ន្ធ CTMS ០១ គ្រឿង
    - ម៉ាស៊ីនភ្លើងបម្រុង (1500KVA) ០៣ គ្រឿង ។

អង្គសន្និបាតបានសម្រាករយៈពេល ១៥ នាទី ដើម្បីរៀបចំបោះឆ្នោតជ្រើសតាំងអភិបាលទាំង ០២ ជាសមាជិកក្រុមប្រឹក្សាភិបាល កសស អាណត្តិទី៧ ឯកឧត្តមប្រធានក្រុមប្រឹក្សាភិបាល និងជាប្រធានមហាសន្និបាត បានប្រកាសកម្មវិធីបន្ទាប់ និងប្រកាសស្នើសុំអោយអង្គសន្និបាត អនុម័តសមាសភាព គណៈកម្មការរៀបចំការបោះឆ្នោត ដើម្បីការបោះឆ្នោតប្រព្រឹត្តទៅដោយតម្លាភាព ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. លោក **ថៃ ឫទ្ធី** | អគ្គនាយករងអាជីវកម្ម | ជាប្រធាន |
| ២. លោក **ឈុន ហុង** | អគ្គនាយករង រដ្ឋបាល-គ្រប់គ្រង | ជាអនុប្រធាន |
| ៣. លោក **ជា យុទ្ធឌីកា** | អគ្គនាយករងបច្ចេកទេស | ជាអនុប្រធាន |
| ៤. លោក **ទី សាគុណ** | នាយក ប/ទ សម្ភារៈ-សំណង់ | ជាអនុប្រធាន |
| ៥. លោកស្រី **សរ ម៉ាលីន** | មន្ត្រី នា. ប/ទ សម្ភារៈ-សំណង់ | ជាសមាជិក |
| ៦. លោក **សួន ប៊ុនសុង** | មន្ត្រី នា. រដ្ឋបាល-ធនធានមនុស្ស | ជាសមាជិក |
| ៧. លោក **អ៊ូ សុវណ្ណឫទ្ធិ** | មន្ត្រី នា. រដ្ឋបាល-ធនធានមនុស្ស | ជាសមាជិក |
| ៨. លោក **តាំង ស៊ុនងួន** | មន្ត្រី នា. អាជីវកម្ម | ជាសមាជិក |
| ៩ លោក **ហ៊ិន ភក្តី** | មន្ត្រី នា. រដ្ឋបាល-ធនធានមនុស្ស | ជាសមាជិក |
| ១០. លោក **ស៊ាប គង្គារ** | មន្ត្រី នា. រដ្ឋបាល-ធនធានមនុស្ស | ជាសមាជិក |
| ១១. លោក **ជា ពិសិដ្ឋមង្គល** | មន្ត្រី នា. ប/ទ សម្ភារៈ-សំណង់ | ជាសមាជិក |
| ១២. លោក **ទៀង រតនា** | មន្ត្រី នា. ប/ទ សម្ភារៈ-សំណង់ | ជាសមាជិក ។ |

អង្គសន្និបាតបានយល់ព្រមលើសមាសភាពគណៈកម្មការរៀបចំការបោះឆ្នោត ដោយលើកដៃអនុម័ត ។

នៅម៉ោង ០៩:៣០ នាទី ឯកឧត្តមប្រធាន បានប្រគល់ភារកិច្ចបន្តជូនគណៈកម្មការរៀបចំការបោះឆ្នោត ដែលមានលោក **ថៃ ឫទ្ធី** ជាប្រធានគណៈកម្មការរៀបចំការបោះឆ្នោត និងសមាជិកចំនួន ១១ រូប ដើម្បីដឹកនាំនិងសម្របសម្រួល ការរៀបចំបោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ។

ជាបឋមលោក **ថៃ ឫទ្ធី** បានឡើងប្រកាសពីចំនួនភាគហ៊ុនិកដែលមានវត្តមានមានចំនួន ១១៩ រូប ស្មើនឹង ៩៥% នៃចំនួនភាគហ៊ុនទាំងមូល ដែលអនុញ្ញាតអោយគណៈកម្មការរៀបចំការបោះឆ្នោតជ្រើសតាំងអភិបាល

ឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន អាចដំណើរការបោះឆ្នោតបាន ។ បន្ទាប់មកទៀត លោក **ថៃ ឫទ្ធី** បានប្រកាសសមាសភាពនៃគណៈកម្មការរៀបចំការបោះឆ្នោត មានចំនួន ១១ រូប ដែលមានវត្តមាន នៅក្នុងអង្គមហាសន្និបាត ។

បន្ទាប់មកទៀត លោកបានឡើងថ្លែងពីបែបបទនៃការបោះឆ្នោត ដោយបានបញ្ជាក់ថាការបោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ធ្វើឡើងដោយសេរី តម្លាភាព និងតាមប្រព័ន្ធឯកត្តនាម ។ ការបោះឆ្នោត ធ្វើឡើងនៅតាមការិយាល័យបោះឆ្នោត ដែលមានចំនួន ០២ ការិយាល័យ រួមមានការិយាល័យបោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ និងការិយាល័យបោះឆ្នោតជ្រើសតាំងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ។ នៅក្នុងការិយាល័យនីមួយៗ មានហិបឆ្នោត ដែលមានបិទឈ្មោះជាភាសាខ្មែរ ជាអក្សរឡាតាំង និងមានបិទរូបថតបេក្ខជនឈរឈ្មោះ ។ ហិបឆ្នោតនៅការិយាល័យបោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ មានពណ៌ខៀវ និងមានចំនួន ៤ ហិបឆ្នោត ។ ហិបឆ្នោតនៅការិយាល័យបោះឆ្នោតជ្រើសតាំងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន មានពណ៌ក្រហម និងមានចំនួន ១ ហិបឆ្នោត ។ ចំណែកសន្លឹកឆ្នោតវិញ មាន ២ ពណ៌ គឺពណ៌ខៀវ សម្រាប់បោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ រីឯពណ៌ក្រហម សម្រាប់បោះឆ្នោតជ្រើសតាំងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ។

លោក **ថៃ ឫទ្ធី** បានរំលឹកដល់ភាគហ៊ុនិកម្នាក់ៗ ត្រូវទម្លាក់បណ្ណបោះឆ្នោត ទៅក្នុងហិបឆ្នោតនៃបេក្ខជនដែលខ្លួនពេញចិត្ត និងត្រូវទម្លាក់ទៅតាមពណ៌នៃបណ្ណបោះឆ្នោត អោយត្រូវគ្នានឹងពណ៌ ហិបឆ្នោត ។ លោកបានបន្ថែមថាការរាប់ និងការបូកសរុបលទ្ធផលបោះឆ្នោត ធ្វើឡើងតាមប្រព័ន្ធកុំព្យូទ័រ ។ ក្រោយបញ្ចប់ការណែនាំពីរបៀបបោះឆ្នោតរួចមក លោកក៏បានប្រកាសប្រាប់អោយបេក្ខជនឈរឈ្មោះជាអភិបាលឯករាជ្យទាំង ០៤ រូប និងបេក្ខជនឈរឈ្មោះជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ០១ រូប រៀបចំខ្លួន ដើម្បីឡើងធ្វើការណែនាំពីសមត្ថភាព បទពិសោធន៍ និងទិសដៅការងារ ជូនអង្គមហាសន្និបាតទាំងមូល ក្នុងគោលបំណងទាក់ទាញការគាំទ្រពីភាគហ៊ុនិក ។

បន្ទាប់មក លោក **ឈុន ហុង** និងលោក **ជា យុទ្ធឌីកា** អនុប្រធានគណៈកម្មការរៀបចំការបោះឆ្នោត បានលើកបង្ហាញជូនហិបឆ្នោតជូនដល់ភាគហ៊ុនិកមានវត្តមានទាំងអស់ ព្រមទាំងបេក្ខជនឈរឈ្មោះជាអភិបាលឯករាជ្យទាំង ០៤ រូប និងបេក្ខជនឈរឈ្មោះជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ០១ រូប ដើម្បីបញ្ជាក់អំពីសុក្រិតភាព និងតម្លាភាព របស់ហិបឆ្នោតទាំង ៥ ។

លោក **ថៃ ឫទ្ធី** បានបញ្ជាក់ជូនគណៈអធិបតី ភ្ញៀវកិត្តិយស ភាគហ៊ុនិកមានវត្តមាន និងបេក្ខជនឈរឈ្មោះបោះឆ្នោតទាំង ០៥ រូប អោយបានជ្រាបថា ការឡើងឃោសនានេះ ក្នុងម្នាក់ មានរយៈពេល ១០ នាទី ហើយការឃោសនារបស់បេក្ខជនម្នាក់ៗ និងត្រូវជៀសវាងការវាយប្រហារ ដែលនាំអោយប៉ះពាល់ដល់បេក្ខជនផ្សេងទៀត។ លោកបានចែកការឡើងឃោសនា ដោយចាប់ផ្តើមដំបូង ពីបេក្ខជនឈរឈ្មោះជាអភិបាលឯករាជ្យ បន្ទាប់មកបេក្ខជនឈរឈ្មោះជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ។

នៅវេលាម៉ោង ០៩:៤៥ នាទី បេក្ខជនជាអភិបាលឯករាជ្យ ចំនួន ០៤ រូប បានឡើងណែនាំសមត្ថភាពបទពិសោធន៍ការងារ ដែលធ្វើឡើងតាមលំដាប់លំដោយ រួមមានបេក្ខជនទី ១ ឯកឧត្តម **សុក ស៊ីផាន់ណា**, បេក្ខជនទី ២ លោក **ជា សំបាត់**, បេក្ខជនទី ៣ លោក **ហ៊ីន មុន្នីវណ្ណ** និងបេក្ខជនទី ៤ លោក **ស៊ឹម ហ៊ុយឈួង** ។

បេក្ខជនទី ១: ឯកឧត្តម **សុក ស៊ីផាន់ណារា** បានឡើងថ្លែងបង្ហាញអំពី លក្ខណៈសម្បត្តិ របស់រូបលោក ក្នុងតួនាទីជា អភិបាលឯករាជ្យ រួមមាន ៖

១. បទពិសោធន៍ការងារ : លោកទើបនឹងបញ្ចប់អាណត្តិជា ប្រធានក្រុមប្រឹក្សាភិបាល របស់វិទ្យាស្ថាន CDRI ព្រមទាំងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ នៃក្រុមហ៊ុន AIA និងក្រុមហ៊ុន ឯកជនជាច្រើនទៀតផងដែរ ។ ម៉្យាងទៀត លោកក៏មានវិជ្ជាជីវៈ មេធាវី, ទីប្រឹក្សាផ្នែកច្បាប់ ផងដែរ ។

២. តួនាទី និងការយល់ដឹងអំពីវិស័យផ្លូវច្បាប់ ពន្ធដារ : ការយល់ដឹង និងបទពិសោធន៍ផ្លូវច្បាប់ ពិតជាមានតម្រូវការសំខាន់ សម្រាប់ដំណើរអាជីវកម្ម កសស ។

បេក្ខជនទី ២: លោក **ខា សំបាត់** បានឡើងថ្លែង អំពីជីវប្រវត្តិផ្ទាល់ខ្លួន និងបទពិសោន៍ការងារ ទាក់ទងនឹងវិស័យកំពង់ផែ តាំងពីការបញ្ចប់ការសិក្សាថ្នាក់វិស្វករ និងចូលបម្រើការងារនៅ កសស នៅឆ្នាំ១៩៨០ និងអភិវឌ្ឍសមត្ថភាពតាមរយៈការសិក្សាទាំងក្នុង និងក្រៅប្រទេសជាបន្តបន្ទាប់ រហូតទទួលបានតួនាទីសំខាន់ជាថ្នាក់ដឹកនាំមួយរូប នៃ កសស ។

បេក្ខជនទី ៣: លោក **ហ៊ុន មុន្នីវណ្ណា** បានបង្ហាញអំពីការសិក្សាថ្នាក់បរិញ្ញាបត្រគ្រប់គ្រង ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យ មហាវេទឫស្សី នៅឆ្នាំ ១៩៩៧ និងបានបន្តការសិក្សា និងបណ្តុះបណ្តាលបន្ថែមទាំងក្នុងប្រទេស និងក្រៅប្រទេស ដែលទាក់ទងនឹងជំនាញ គណនេយ្យនិងហិរញ្ញវត្ថុ ។ ចំពោះ បទពិសោធន៍ការងារ លោកបានធ្លាប់ និងកំពុងធ្វើការក្នុងឋានៈជាសមាជិកក្រុមប្រឹក្សាភិបាលផង ក៏ដូចជាអភិបាលឯករាជ្យ នៅក្នុងក្រុមហ៊ុន, ធនាគារ, ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងវិទ្យាស្ថាន ជាច្រើនតួយ៉ាងមានដូចជា ជាសមាជិកក្រុមប្រឹក្សាភិបាលនៃ Australian Institute of Company Director (AICD), ធ្លាប់ជាប្រធានគណៈកម្មការ សវនកម្ម នៃធនាគារ ស្ថាបនា, ជាប្រធានក្រុមប្រឹក្សាភិបាល Mega Leasing ឆ្នាំ ២០១៣ និងបានបង្កើតក្រុមហ៊ុន ប្រមូលទិញហ៊ុន ក្នុងប្រទេសកម្ពុជា (CIC) ដើម្បីវិនិយោគ ក្នុងទីផ្សារប្រទេសកម្ពុជា ។ លោកក៏បានរៀបរាប់បន្ថែម អំពីបទពិសោធន៍ការងារ ក្នុងវិស័យឯកជនក្នុង និងក្រៅប្រទេសជាច្រើន ដែលពាក់ព័ន្ធជំនាញសវនកម្ម ហិរញ្ញវត្ថុ និងការងារគ្រប់គ្រងក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាល ជាអ្នកគ្រប់គ្រងទូទៅ និងជាស្ថាបនិកក្រុមហ៊ុន ក៏ដូចជានាយកហិរញ្ញវត្ថុ នៅសិប្បករ អង្គរ-Artisan D'angkor ជាដើម ។

បេក្ខជនទី ៤: លោក **ស៊ឹម ហ៊ុយឈួន** បានឡើងថ្លែង ជាកិត្តិយសរបស់ខ្លួនដែលបានក្នុងការប្រកួតប្រជែងជាបេក្ខជនឈរឈ្មោះបោះឆ្នោត អភិបាលឯករាជ្យ និងបានបង្ហាញអំពីប្រវត្តិសិក្សា និងបទពិសោធន៍ការងាររបស់លោកតាំងពីឆ្នាំ ២០០៦ មានដូចជា បញ្ចប់ការសិក្សាពីគណនេយ្យករជំនាញ ACCA នៅឆ្នាំ ២០០៦, ធនាគារ កាណាឌីយ៉ា, ការងារផ្នែកវិនិយោគ Leopard Investment Capital Co., Ltd, ជា Senior Investment Consultant នៅ Devenco Management and Consulting Firm, ជាសមាជិកក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិនៃ Prince Finance PLC, ជាសមាជិកសាមញ្ញ នៃសមាគម IAMBD ។

បន្ទាប់ពីបញ្ចប់ការបង្ហាញខ្លួនរបស់បេក្ខជនជាអភិបាលឯករាជ្យរួចមកលោក **ថៃ ឬទ្ធី** ប្រធានគណៈកម្មការរៀបចំការបោះឆ្នោត បានផ្តល់ឱកាសដូចគ្នាជូនដល់បេក្ខជនឈរឈ្មោះជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ដើម្បីបានណែនាំខ្លួន និងបទពិសោធន៍ជូនអង្គមហាសន្និបាត ។ បេក្ខជនដែលឈរឈ្មោះជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន មានចំនួន ១ រូប គឺលោក Hidetoshi KUME ។

បេក្ខជនតែ ១ រូប គត់ គឺលោក Hidetoshi KUME បានឡើងថ្លែងអំពីប្រវត្តិរូបសង្ខេប និងបទពិសោធន៍ការងារ ជាមន្ត្រី JICA ដែលបានចូលរួមធ្វើការជាមួយស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា រួមមាន ក្រសួងសាធារណការ និងដឹកជញ្ជូន, កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស), កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ) និងភ្នាក់ងារនាវាចរកម្ពុជា (កាំសាប) ដើម្បីធ្វើការ និងដោះស្រាយការងារគម្រោងជាច្រើនដូចជា ការងារភស្តុភារ, ការងារប្រព័ន្ធរដ្ឋបាលគ្រប់គ្រងកំពង់ផែ, ការសិក្សាអំពី Port EDI, ការងារស្រង់គំនូសសម្រាប់នាវាសម្រាប់ការចូល-ចេញ នៅ-ពីកំពង់ផែ និងការងារហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជា ។ គាត់ក៏បានផ្តល់អំពីគំនិត និងទស្សនៈវិស័យរបស់រូបលោកក្នុងដំណើរការអាជីវកម្មរបស់ កសស នៅពេលដែលរូបលោកក្លាយជា អភិបាលមិនប្រតិបត្តិរបស់ កសស ។ គាត់ក៏បញ្ជាក់ជូនឯកឧត្តមគណៈអធិបតី និងភាគហ៊ុនិក កសស ទាំងអស់ថា គាត់មិនត្រឹមតែធ្វើការសម្រាប់ JICA តែមួយប៉ុណ្ណោះទេ តែគាត់នឹងធ្វើការបម្រើជូនភាគហ៊ុនិក កសស ទាំងអស់ ដើម្បីអភិវឌ្ឍ កសស អោយរីកចម្រើនទៅមុខ ។

ក្រោយពីបញ្ចប់ការឃោសនាពីសមត្ថភាព បទពិសោធន៍ការងារ និងប្រវត្តិនៃការសិក្សា របស់បេក្ខជនទាំង ០៥ រូប នៅម៉ោង ១០:៣០ នាទី លោក **ថៃ ឫទ្ធី** ប្រធានគណៈកម្មការរៀបចំការបោះឆ្នោត បានជូនតួនាទីទៅលោក **ទី សាគុណា** ដើម្បីរៀបរាប់ពីលក្ខខណ្ឌ និងនីតិវិធី ក្នុងដំណើរការបោះឆ្នោត ជូនដល់ភាគហ៊ុនិកដើម្បីប្រព្រឹត្តិទៅដោយត្រឹមត្រូវ សេរី និងមានតម្លាភាព ក្នុងកិច្ចប្រជុំមហាសន្និបាត និងបានប្រកាសចាប់ផ្តើមការបោះឆ្នោត ដោយក្នុងនោះ បានស្នើសុំអង្គមហាសន្និបាតអនុញ្ញាតអោយ ឯកឧត្តមប្រធានមហាសន្និបាត, ឯកឧត្តមតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សមាជិកក្រុមប្រឹក្សាភិបាល, តំណាង JICA, សមាជិកគណៈកម្មការរៀបចំការបោះឆ្នោតឡើងទៅបោះឆ្នោតមុន ។ បន្ទាប់មក គណៈកម្មការរៀបចំការបោះឆ្នោត បានហៅឈ្មោះភាគហ៊ុនិកតាមបញ្ជីឈ្មោះចុះវត្តមានឡើងទៅបោះឆ្នោត ដោយក្នុងមួយលើកៗចំនួន ១០ (ដប់) រូប ។

នៅម៉ោង ១១:០០ នាទី ការបោះឆ្នោតបានបញ្ចប់ប្រកបដោយដំណើរការរលូន និងមានរបៀបរៀបរយល្អ ។ បន្ទាប់មក គណៈកម្មការរៀបចំការបោះឆ្នោត បានចាប់ផ្តើមរាប់សន្លឹកឆ្នោតរបស់បេក្ខជននីមួយៗ ដោយប្រព័ន្ធកុំព្យូទ័រ (ប្រព័ន្ធ Barcode) ។

បន្ទាប់មក ឯកឧត្តមប្រធានមហាសន្និបាត បានប្រកាសលទ្ធផល នៃការបោះឆ្នោតសម្រាប់បេក្ខជននីមួយៗដូចខាងក្រោម ៖

**ទី១.លទ្ធផលឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ**

បេក្ខជនទី១ ឯកឧត្តម **សុក ស៊ីផាន់ណា** ទទួលបានចំនួន ១៤.២៨២.៦២២ សំឡេង
បេក្ខជនទី២ លោក **ខា សំបាត់** ទទួលបានចំនួន ៤១៧.៤៩២ សំឡេង
បេក្ខជនទី៣ លោក **ហ៊ុន មុន្នីវណ្ណា** ទទួលបានចំនួន ៦៦.៤៣២.០៣៧ សំឡេង
បេក្ខជនទី៤ លោក **ស៊ឹម ហ៊ុយឈួន** ទទួលបានចំនួន ៣៤២.១៨៧ សំឡេង

**ទី២.លទ្ធផលឆ្នោតជ្រើសតាំងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន**

បេក្ខជនទី១ លោក Hidetoshi KUMEទទួលបានចំនួន ១៧.០៧៦.៤៦៣ សំឡេង

ដូចនេះ ជាលទ្ធផលនៃការបោះឆ្នោត អង្គសន្និបាតបានសម្រេចដូចខាងក្រោម ៖

- បេក្ខជនដែលជាប់អភិបាលឯករាជ្យ គឺលោក **ហ៊ុន មុន្នីវណ្ណា** និង
- បេក្ខជនដែលជាប់ជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន គឺលោក Hidetoshi KUME.

ចំណែក សន្លឹកឆ្នោតឥតបានការ មានចំនួន ០២ (ពីរ) សន្លឹក ។

នៅម៉ោង ១១:៤០ នាទី ឯកឧត្តមប្រធានមហាសន្និបាតភាគហ៊ុនិក បានថ្លែងសុន្ទរកថាបិទមហាសន្និបាតភាគហ៊ុនិកលើកទី១ និងបានបញ្ជាក់អោយឃើញថា កសស ពិតជាសហគ្រាសសាធារណៈ ដែលកំពុងដើរស្របតាមគោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា ប្រកបដោយតម្លាភាព និងទទួលបានការជឿទុកចិត្តពីសំណាក់សាធារណជន ជម្រុញអោយ កសស សម្រេចនូវសមិទ្ធិផលជាច្រើន និងកំពុងដើរតួនាទីកាន់តែមានសារៈសំខាន់ទ្បើង សម្រាប់បម្រើអោយចរន្តសេដ្ឋកិច្ចជាតិ និងពង្រឹងឧត្តមភាពនៃការប្រកួតប្រជែងរបស់កម្ពុជានៅក្នុងតំបន់ និងពិភពលោក។

ជាចុងបញ្ចប់ ឯកឧត្តមប្រធានមហាសន្និបាត តាងនាមក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក កម្មករ កសស ទាំងអស់ ក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នឹងឈានចូលមកដល់ខាងមុខនេះ សូមបួងសួងដល់ទេវតាឆ្នាំថ្មីជូនពរជ័យមហាប្រសើរ និងគោរពជូនពរដល់ ឯកឧត្តម គណៈអធិបតី ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ ព្រមទាំងភាគហ៊ុនិកទាំងអស់ ទទួលបាននូវពុទ្ធពរទាំង ៥ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ជាពិសេស ទទួលបានសុខភាពល្អ និងសុភមង្គលគ្រប់ក្រុមគ្រួសារ ។

អង្គមហាសន្និបាតភាគហ៊ុនិកលើកទី១ បានបិទបញ្ចប់នៅវេលាម៉ោង ១១:៥០ នាទី នៅថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសរីករាយស្និទ្ធស្នាល ប្រកបដោយភាពរលូន មានរបៀបរៀបរយ និងការទទួលខុសត្រូវខ្ពស់ ។

លេខាកត់ត្រា

រ័ត្ន សិលា

បានឃើញ និងឯកភាព

**ប្រធានគណៈកម្មការរៀបចំការបោះឆ្នោត**

**ថៃ ឫទ្ធី**

បានឃើញ និងឯកភាព

**ប្រធានមហាសន្និបាត**

**លូ_គឹមឈន់**